**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**មន្ទីរសាធារណការ និងដឹកជញ្ជូន**
**ខេត្តកំពង់ធំ**

លេខ:...៣០៣.......សជណ.សក.កធ

## សេចក្តីជូនដំណឹង
## ស្តីពីកាលបរិច្ឆេទនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត
## ដោយប្រើប្រាស់ម៉ាស៊ីនត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័ត

**យោង**:-សេចក្តីជូនដំណឹងលេខ ៤២៨ សក.ដជគ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ។

មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ធំ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អស់លោក លោកស្រីជាម្ចាស់យានយន្តទាំងអស់ ដែលពុំទាន់បានធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ឱ្យបានជ្រាបថា៖ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋលើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក បានសម្រេចឱ្យក្រុមហ៊ុន HK Car inspection Co¸ Ltd ប្រើប្រាស់ម៉ាស៊ីន ត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័ត ដើម្បីត្រួតពិនិត្យ លក្ខណៈបច្ចេកទេសតាមបណ្តាខេត្ត ដោយប្រើម៉ាស៊ីនត្រួតពិនិត្យលក្ខណៈបច្ចេកទេស នឹងមកដល់ខេត្តកំពង់ធំ៖

លើកទី ១ : នៅថ្ងៃទី ១០ ដល់ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៧
លើកទី ២ : នៅថ្ងៃទី ១៧ ដល់ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៧
លើកទី ៣ : នៅថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៧

*ដែលមានទីតាំងនៅភូមិ ថ្នល់បែក ឃុំត្រពាំងឬស្សី ស្រុក កំពង់ស្វាយ ខេត្តកំពង់ធំ ( នៅតាមផ្លូវជាតិលេខ ៦ មុខស្ថានីយប្រេងតេលាថ្នល់បែក សៀមរាប ព្រះវិហារ)* ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអស់លោក/លោកស្រី មេត្តាត្រៀមយកយានយន្ត របស់ខ្លួន មកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមកាលបរិច្ឆេទ និងទីតាំងដូចបានជម្រាប ជូនខាងលើតាមការគួរ ។

-**សូមបញ្ជាក់:** ចំពោះម្ចាស់យានយន្តចាស់ត្រូវយកជាប់មកជាមួយនូវ វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចាស់ និងCOPY ប័ណ្ណសំគាល់យានយន្ត ( កាតគ្រី )មួយសន្លឹក ។

-ចំពោះម្ចាស់យានយន្តថ្មី ត្រូវ COPY សន្លឹកពន្ធនាំចូល០១សន្លឹក និងCOPYអត្តសញ្ញាណប័ណ្ណចំនួន០១សន្លឹក ។

កំពង់ធំ,ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧
**ប្រធានមន្ទីរ**

ជុំ-កុណ្ណា

**<u>ចម្លងជូន៖</u>**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ
- សាលាខេត្តកំពង់ធំ
- ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ធំ

**-ដើម្បីគោរពជូនជ្រាប-**
- មន្ទីរពត៌មានខេត្តកំពង់ធំ
- សាលាក្រុងស្ទឹងសែន និងស្រុកទាំង ០៧
- ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក

**-ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ-**

-ឯកសារ-កាលប្បវត្តិ-